ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

លេខ ០៤៤០ ព.ណ.ភព.

ថ្ងៃច័ន្ទ ៧រោច ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែកុម្ភៈ ឆ្នាំ ២០២៦

# សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្មមានកិត្តិយសសូមជម្រាបជូនដំណឹងដល់ លោក-លោកស្រី ជាអាជីវករ ផលិតករ អ្នកផ្គត់ផ្គង់ អ្នកកែច្នៃ ប្រធាន/សមាជិកសហគមន៍កសិកម្ម ម្ចាស់កសិដ្ឋាន អ្នកដាំដុះបន្លែផ្លែឈើ និងសាធារណជនទូទៅឱ្យបានជ្រាបថា ក្រសួងពាណិជ្ជកម្មនឹងបន្តរៀបចំ **«ពិព័រណ៍ផលិតផលខ្មែរ និងបន្លែផ្លែឈើ លើកទី១៩» ឆ្នាំ២០២៦ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី២៦ ខែកុម្ភៈ ដល់ថ្ងៃទី១ ខែមីនា ឆ្នាំ២០២៦** នៅបរិវេណសួនហាត់ប្រាណមាត់ស្ទឹងសៀមរាប ខេត្តសៀមរាប។

ក្រសួងពាណិជ្ជកម្មរៀបចំព្រឹត្តិការណ៍ពិព័រណ៍នេះឡើង ក្នុងគោលបំណង ១-ជំរុញផលិតកម្មក្នុងស្រុក ២-បន្តគាំទ្រផលិតផលខ្មែរ ៣-អភិវឌ្ឍន៍វិស័យឯកជន និង៤-បង្កើតវេទិកាផ្គូផ្គងពាណិជ្ជកម្មរវាងសហគមន៍កសិកម្ម ម្ចាស់កសិដ្ឋាន អ្នកដាំដុះបន្លែផ្លែឈើ ជាមួយនឹងអ្នកចែកចាយ អ្នកលក់ដុំ-រាយ អ្នកកែច្នៃ និងម្ចាស់អាជីវកម្មនានា ស្របតាមផែនការសកម្មភាពការងាររបស់ក្រសួងពាណិជ្ជកម្ម និងស្របតាមគោលនយោបាយ និងយុទ្ធសាស្រ្តបញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលកម្ពុជា។ ក្នុងន័យនេះ ក្រសួងពាណិជ្ជកម្ម សូមអញ្ជើញ លោក-លោកស្រី ជាអាជីវករ ផលិតករ អ្នកផ្គត់ផ្គង់ អ្នកកែច្នៃ សហគមន៍កសិកម្ម ម្ចាស់កសិដ្ឋាន អ្នកដាំដុះបន្លែផ្លែឈើ ចូលរួមដាក់តាំងបង្ហាញ-លក់ផលិតផល និងស្វែងរកដៃគូពាណិជ្ជកម្ម ដើម្បីឈានទៅការចុះកិច្ចសន្យាទិញ-លក់ ក្នុងព្រឹត្តិការណ៍ពិព័រណ៍ខាងលើ។

សម្រាប់ការចុះឈ្មោះចូលរួម សូម លោក-លោកស្រី ធ្វើការទំនាក់ទំនងមកនាយកដ្ឋានកិច្ចការពិព័រណ៍នៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម ដែលមានទីតាំងស្ថិតនៅជាន់ទីពីរ ទីស្តីការក្រសួងពាណិជ្ជកម្ម អាសយដ្ឋានៈ ដីឡូត៍លេខ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឬតាមទូរស័ព្ទលេខៈ ០៧០ ៩៤ ០៦ ០៦ ឬ ០៧៧ ៣៣ ៩៤ ៣៩ ឬមន្ទីរពាណិជ្ជកម្មខេត្តសៀមរាប តាមទូរស័ព្ទលេខ ០៧៧ ៥៩ ៩៩ ៦៣ ឬបំពេញបែបបទតាមអនឡាញ តាមរយៈតំណរភ្ជាប់ https://shorturl.at/KeYfu។

**សូមអរគុណ!**

សម្រាប់ចុះឈ្មោះ:

https://go.gov.kh/moc/vhorrk

GO.gov.KH

ព្រះរាជាណាចក្រកម្ពុជា

ក្រសួងពាណិជ្ជកម្ម

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

## ពាក្យសុំចុះឈ្មោះចូលរួម
## «ពិព័រណ៍ផលិតផលខ្មែរ និងបន្លែផ្លែឈើ លើកទី១៩» ឆ្នាំ២០២៦

បរិវេណសួនហាត់ប្រាណមាត់ស្ទឹងសៀមរាប ខេត្តសៀមរាប
ថ្ងៃទី២៦ ខែកុម្ភៈ ដល់ថ្ងៃទី១ ខែមីនា ឆ្នាំ២០២៦

### ១.ព័ត៌មានអំពីក្រុមហ៊ុន

| | |
|---|---|
| ឈ្មោះក្រុមហ៊ុន | ............................................................................................................... |
| ឈ្មោះប្រធានក្រុមហ៊ុន | ............................................................................................................... |
| អាសយដ្ឋានក្រុមហ៊ុន | ............................................................................................................... |
| ទូរស័ព្ទ | ............................................................................................................... |
| អ៊ីម៉ែល | ............................................................................................................... |

### ២.ព័ត៌មានអំពីប្រភេទផលិតផល

| ប្រភេទផលិតផល | | រាយមុខផលិតផល |
|---|---|---|
| បន្លែផ្លែឈើ | ☐ | ............................................................................................ |
| កសិផលកែច្នៃ | ☐ | ............................................................................................ |
| កសិ-ឧស្សាហកម្ម | ☐ | ............................................................................................ |
| គម្រោងវិនិយោគកសិកម្ម | ☐ | ............................................................................................ |
| សហគមន៍កសិកម្ម | ☐ | ............................................................................................ |
| កសិដ្ឋាន | ☐ | ............................................................................................ |
| វត្ថុអនុស្សាវរីយ៍ | ☐ | ............................................................................................ |
| ផ្សេងៗ..... | ☐ | ............................................................................................ |

### ៣-លក្ខខណ្ឌនៃការចូលរួម

-ត្រូវរៀបចំស្តង់របស់ខ្លួនឱ្យបានរួចរាល់មួយថ្ងៃ មុនពេលបើកសម្ពោធពិព័រណ៍

-មិនអនុញ្ញាតឱ្យតាំងបង្ហាញ/លក់ផលិតផលផ្សេង ក្រៅពីផលិតផលខ្មែរ ឬផលិតផលផលិតនៅកម្ពុជា និងផលិតផលដែលមិនមានបំពេញនៅក្នុងបែបបទខាងលើ

-មិនអនុញ្ញាតផ្ទេរស្តង់ ឬទុកស្តង់ឱ្យនៅទំនេរក្នុងរយៈពេលនៃការតាំងពិព័រណ៍

ក្នុងករណីមិនបានអនុវត្តតាមការណែនាំខាងលើ គណៈកម្មការមានសិទ្ធិបិទស្តង់ ឬដកហូតស្តង់មកវិញ ហើយរាល់ការចំណាយសាងសង់ស្តង់ជាបន្ទុករបស់ម្ចាស់ស្តង់។

ខ្ញុំបាទ/នាងខ្ញុំ ជាប្រធាន/តំណាងក្រុមហ៊ុន សូមធានាអះអាងថា ព័ត៌មានខាងលើពិតជាត្រឹមត្រូវពិតប្រាកដមែន និងសូមអនុវត្តតាមលក្ខខណ្ឌនៃការចូលរួមខាងលើ។ បើខុសពីការពិត ខ្ញុំបាទ/នាងខ្ញុំ សូមទទួលខុសត្រូវចំពោះមុខច្បាប់៕

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២៦

**ប្រធាន/តំណាងក្រុមហ៊ុន**

ហត្ថលេខា និងត្រា

ទំនាក់ទំនង៖ លោក ស្រី ណូរ៉ា៖ ០៧០ ៩៤ ០៦ ០៦
លោកស្រី អេង សុនារី៖ ០៧៧ ៣៣ ៩៤ ៣៩